ព្រះកន្សែងនៃព្រះទ័យព្រះបិតាតាំងពីកំណើតពិភពលោកដល់វិវរណៈ...

# សំបុត្រស្នេហា នៃព្រះបិតា

## កូនសំលាញ់បិតា...

ប្រហែលជាកូនមិនស្គាល់បិតាទេ

ប៉ុន្តែបិតាស្គាល់កូនយ៉ាងច្បាស់...ទំនុកតំកើង ១៣៩:១ បិតាជ្រាបពេលណាដែលកូនអង្គុយ

ពេលណាដែលកូនក្រោកឈរ...ទំនុកតំកើង ១៣៩:២ បិតាជ្រាបច្បាស់នូវអ្វីៗដែលកូនប្រព្រឹត្ត...ទំនុកតំកើង ១៣៩:៣ សូម្បីតែសក់ នៅលើក្បាលកូនក៏បិតារាប់អស់ដែរ...ម៉ាថាយ ១០:២៩-៣១ បិតាបង្កើតកូនមកជាតំណាងបិតាផ្ទាល់...កំណើតពិភពលោក ១:២៧ ដ្បិតកូនមានជីវិត ចលនា និង មានភាវៈជាមនុស្សក៏ដោយសារបិតា...កិច្ចការ ១៧:២៨ កូនជាពូជពង្សរបស់បិតាដែរ...កិច្ចការ ១៧:២៨ បិតាស្គាល់កូនតាំងពីមុនពេលដែលបិតាបានសូនកូនក្នុងផ្ទៃម្ដាយម្ល៉េះ...យេរេមី ១:៤-៥ បិតាបានជ្រើសរើសកូនទុកដោយឡែកស្របតាមផែនការបិតា...អេភេសូ ១:១១-១២ កូនមិនមែនកើតមកក្នុងលោកនេះដោយចៃដន្យទេ...ទំនុកតំកើង ១៣៩:១៥-១៦ បិតាបានកំណត់ចំនួនថ្ងៃនៃអាយុជីវិតរបស់កូនទុកក្នុងបញ្ជីបិតា...ទំនុកតំកើង ១៣៩:១៥-១៦ បិតាបានកំណត់រដូវកាល និង កំណត់ព្រំដែនអោយកូនរស់នៅ...កិច្ចការ ១៧:២៦ ដ្បិតកូនជាស្នាព្រះហស្តដ៏អស្ចារ្យរបស់បិតា...ទំនុកតំកើង ១៣៩:១៤ បិតាបានបង្កប់កូននៅក្នុងផ្ទៃម្ដាយរបស់កូន...ទំនុកតំកើង ១៣៩:១៣ គឺព្រះបិតាហើយដែលបានយកកូនចេញពីផ្ទៃម្ដាយ...ទំនុកតំកើង ៧១:៦ ដ្បិតអ្នកមិនស្គាល់បិតា មិនបានធ្វើជាតំណាងបិតាឡើយ...យ៉ូហាន ៨:៤១-៤៤ បិតាមិនបានស្ថិតនៅឆ្ងាយពីកូន ហើយក៏មិនខឹងនឹងកូនដែរ តែបិតាជាសេចក្ដីស្រលាញ់...១យ៉ូហាន ៤:១៦ សូមដឹងថា បិតាមានព្រះហឫទ័យស្រលាញ់កូនខ្លាំងណាស់...១យ៉ូហាន ៣:១ គឺកូនជាបុត្ររបស់បិតា ហើយបិតាជាបិតារបស់កូនដែរ...១យ៉ូហាន ៣:១ បិតាសព្វព្រះទ័យប្រទានអ្វីៗដ៏ល្អៗអោយទៅកូនជាង អ្វីៗដែលឪពុកកូនដែលរស់នៅលើផែនដីនេះទៅទៀត...ម៉ាថាយ ៧:១១ បិតាជាព្រះបិតាគ្រប់លក្ខណ៍...ម៉ាថាយ ៥:៤៨ គ្រប់អំណោយដ៏ល្អវិសេស និង អ្វីៗទាំងប៉ុន្មានដ៏គ្រប់លក្ខណៈដែលកូនបានទទួលសុទ្ធតែមកពីព្រះហស្តបិតាទាំងអស់...យ៉ាកុប ១:១៧ បិតាជ្រាបនូវអ្វីៗដែលកូនត្រូវការ ហើយបិតានឹងប្រទានរបស់ទាំងនោះដល់កូន...ម៉ាថាយ ៦:៣១-៣៣ គំរោងការណ៍ដែលបិតាបានផ្ដល់អោយកូននឹងបានសំរេចដោយសេចក្ដីសង្ឃឹម... យេរេមី ២៩:១១ បិតាស្រលាញ់កូនដោយចិត្តស្រលាញ់ដែលស្ថិតស្ថេរនៅអស់កល្បជានិច្ច...យេរេមី ៣១:៣ ព្រះតំរិះបិតាជ្រៅជ្រះណាស់ ព្រោះមានច្រើនជាងគ្រាប់ខ្សាច់ទៅទៀត...ទំនុកតំកើង ១៣៩:១៧-១៨ ដោយព្រោះតែកូន បិតាច្រៀងយ៉ាងរីករាយបំផុត...សេផានី ៣:១៧ បិតានឹងមិនបែរចេញពីកូនទេ បិតានឹងផ្ដល់សេចក្ដីសុខអោយកូនរហូត...យេរេមី ៣២:៤០ កូនជាបុត្ររបស់បិតាផ្ទាល់...សេរីភាព ១៩:៥ បិតានឹងយកចិត្តទុកដាក់ចំពោះកូនអស់ពីលទ្ធភាពបិតា...យេរេមី ៣២:៤១ បិតានឹងសំដែងអោយកូនដឹងអំពីការអស្ចារ្យផ្សេងៗជាការលាក់កំបាំងដែលកូនពុំធ្លាប់ដឹងពីមុនមក...យេរេមី ៣៣:៣ ប្រសិនបើកូនស្វែងរកបិតាយ៉ាងអស់ពីចិត្ត អស់ពីព្រលឹង នោះកូនមុខជាឃើញបិតាមិនខាន...ទុតិយកថា ៤:២៩ ចូរស្វែងរកសុភមង្គលពីបិតា នោះបិតានឹងប្រោសប្រទាននូវអ្វីៗដែលកូនប្រាថ្នាចង់បាន...ទំនុកតំកើង ៣៧:៤ ដ្បិតបិតាទេតើ ដែលធ្វើអោយកូនមានទាំងបំណង...ភីលីព ២:១៣ បិតាអាចធ្វើអ្វីៗទាំងអស់ហួសពីសេចក្ដីសុំ និង ហួសពីអ្វីៗដែលកូននឹកគិត...អេភេសូ ៣:២០ ដ្បិតបិតាជាអ្នកលើកទឹកចិត្តកូន...២ថេស្សឡូនិក ២:១៦-១៧ បិតាជាអ្នកសំរាលទុក្ខកូន នៅពេលកូនមានទុក្ខវេទនាសព្វបែបយ៉ាង...២កូរិនថូស ១:៣-៤ ពេលដែលកូនក្រំចិត្ត បិតានៅជិតកូន...ទំនុកតំកើង ៣៤:១៩ បិតានឹងថែរក្សាកូន ដូចអ្នកគង្វាលថែរក្សាហ្វូងចៀមរបស់ខ្លួនដូច្នោះដែរ...អេសាយ ៤០:១១ ថ្ងៃមួយបិតានឹងជូតទឹកភ្នែកចេញអស់ពីភ្នែករបស់កូន...វិវរណៈ ២១:៣-៤ បិតានឹងដកគ្រប់អស់ទាំងទុក្ខលំបាកដែលកូនបានទទួលនៅផែនដីចេញពីកូនដែរ...វិវរណៈ ២១:៤ បិតាជាបិតារបស់កូន បិតាស្រលាញ់កូន ដូចបិតាស្រលាញ់បុត្រាតែមួយអង្គរបស់បិតាដែរ គឺព្រះយេស៊ូ...យ៉ូហាន ១៧:២៣ ដ្បិតបិតាបានបង្ហាញសេចក្ដីស្រលាញ់របស់បិតាតាមរយៈព្រះយេស៊ូ...យ៉ូហាន ១៧:២៦ ដ្បិតអីព្រះបុត្រា ជារស្មីនៃសិរីរុងរឿងរបស់បិតា និង មានលក្ខណៈដូចបិតាបេះបិទ...ហេព្រើ ១:៣ ហើយព្រះបុត្រាយាងមកដើម្បីសំដែងអោយកូនឃើញថា បិតាកាន់ខាងកូនហើយ តើអ្នកណានឹងចោទប្រកាន់កូនបាន?...រ៉ូម ៨:៣១ បិតាសព្វព្រះទ័យអោយកូនដឹងថា បិតាមិនប្រកាន់ទោសកូនឡើយ...២កូរិនថូស ៥:១៨-១៩ ព្រះយេស៊ូសុគតក៏ដើម្បីអោយ កូនជានានឹងបិតាវិញ...២កូរិនថូស ៥:១៨-១៩ ការបូជាព្រះជន្មព្រះបុត្រា គឺជាការបញ្ជាក់អំពីសេចក្ដីស្រលាញ់របស់បិតាចំពោះកូន...១យ៉ូហាន ៤:១០ បិតាបានលះបង់ អ្វីៗទាំងអស់ដែលបិតាសព្វព្រះហឫទ័យបំផុត ព្រោះបិតាចង់បានសេចក្ដីស្រលាញ់ពីកូនវិញ...រ៉ូម ៨:៣២ ប្រសិនបើកូនទទួលព្រះបុត្រាបិតា គឺព្រះយេស៊ូ នោះកូនក៏បានទទួលបិតាដែរ...១យ៉ូហាន ២:២៣ ហើយក៏គ្មានអ្វីអាចបំបែកសេចក្ដីស្រលាញ់របស់បិតាចេញពីកូនបានដែរ...រ៉ូម ៨:៣៨-៣៩ ចូរវិលត្រលប់ មកបិតាវិញ នោះបិតានឹងធ្វើពិធីជប់លៀងមួយដ៏គគ្រឹកគគ្រេងដែលនៅស្ថានសួគ៌ពុំធ្លាប់ឃើញមានពីមុនមក...លូកា ១៥:៧ បិតាជាបិតារបស់កូនតាំងពីមុនមកម្ល៉េះ ហើយបិតាក៏នៅតែជាបិតារបស់កូនរហូត...អេភេសូ ៣:១៤-១៥ ជាចុងក្រោយនេះ បិតាមានសំនួរមួយសួរកូន តើកូនចង់ ធ្វើជាកូនបិតាទេ?...យ៉ូហាន ១:១២-១៣

បិតាទន្ទឹងរង់ចាំកូនឆ្លើយតបមកបិតាវិញ...លូកា ១៥:១១-៣២

**ពីសេចក្ដីស្រលាញ់នៃព្រះបិតា**

**ព្រះដ៏មានគ្រប់ព្រះចេស្ដា**

Used by permission Father Heart Communications Copyright 199 www.FathersLoveLetter.com